# សេចក្តីប្រកាសព័ត៌មាន

# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# កម្មវិធីប្រលងកំពូលជើងឯកចម្រៀងណូដូជីម៉ាន់

ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១៦

នៅក្នុងឱកាសមហោស្រពគីហ្សូណាជប៉ុន-កម្ពុជាឆ្នាំ២០១៦ ស្ថានទូតជប៉ុនរួមសហការណ៍ជាមួយ មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន(CJCC) បានរៀបចំនូវការប្រលងកំពូលជើងឯកចម្រៀងណូដូជីម៉ាន់ជាលើកដំបូងបំផុតនៅប្រទេសកម្ពុជា។ ព្រឹត្តិការណ៍នេះបានទទួលការឧបត្ថម្ភដោយធនាគារកម្ពុជាសាធារណៈ ក្រុមហ៊ុនទេសចរណ៍ជប៉ុនអេច អាយអេស ក្រុមហ៊ុនយ៉ាមាហាម៉ូតូ ក្រុមហ៊ុន Forval Cambodia សាលាតូរ្យតន្ត្រី Soundskool ក្រុមហ៊ុន Fox Service Union Tourist ក្រុមហ៊ុន MATES Global Communications អង្គការស៊ីសេហ្វ ក្រុមហ៊ុន Terra Motors ក្រុមហ៊ុន Image Printing ភោជនីយដ្ឋានម៉ារីហ្កាមិអ៊ុដុង ភោជនីយដ្ឋានសាច់អាំងជប៉ុនយ៉ាគីនិគឹហ្គាខៃនសិគិ ភោជនីយដ្ឋានសឹសឹមិ ហាងឆាយអង្គរ ក្រុមហ៊ុនGATSBY និង ក្រុមហ៊ុនខ្មែររ៉ាប៊ីត។



រូបថតបេក្ខជន គណៈកម្មការនិងតារាចម្រៀងកិត្តយស

បេក្ខជនជ័យលាភីពីលេខ១ ដល់លេខ៣ក្នុងរយៈពេល៥ឆ្នាំ ដែលមានចំនួន១១រូប បានវិលត្រលប់មកកាន់វេទិកាប្រកួតម្តងទៀត។

**បេក្ខជនដែលទទួលបានជ័យលាភីពីការប្រកួតចម្រៀងជើងឯកមានដូចខាងក្រោម÷**

១- លោកចេត ចាន់សុធា កំពូលជើងឯកជ័យលាភីលេខ១

២- លោកស្រ៊ុន វ៉ាន់ឌី ជ័យលាភីជើងឯកលេខ២

៣- កញ្ញា អ៊ុន ច័ន្ទវាសនា ជ័យលាភីជើងឯកលេខ៣

**បេក្ខជនដែលទទួលបានរង្វាន់ពិសេសរួមមាន÷**

១- លោកប៉ោ ស៊ីណា ទទួលបានរង្វាន់ឯកអគ្គរាជទូត

២- លោកប៊ុន ឈានលីហ៊ាង ទទួលបានរង្វាន់បញ្ចេញសំនៀងភាសាជប៉ុនបានល្អលេខ១

៣- លោក ឌុន ថាតណី ទទួលបានរង្វាន់បញ្ចេញសំនៀងភាសាជប៉ុនបានល្អលេខ២

៤- លោក កៅ និរោធន៍ ទទួលបានរង្វាន់ច្រៀងត្រូវចង្វាក់ភ្លេង

៥- កុមារី ព្រះច័ន្ទ អ៊ីណុគុជិ ទទួលបានរង្វាន់សម្តែងកាយវិការបានល្អលេខ១

៦- លោក ថាន អារុណរ៉េនបូ ទទួលបានរង្វាន់សម្តែងកាយវិការបានល្អលេខ២

អ្នកទស្សនាយ៉ាងច្រើនកុះករក៏បានរីករាយជាមួយចម្រៀងរបស់តារាកិត្តិយសដូចជា លោក នីកូ ជាតារាចម្រៀងដ៏មានប្រជាប្រិយភាពប្រចាំប្រទេសកម្ពុជា លោក ញ៉ឹង កាណុល មកពីសកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ លោក Gosuke Uno និង កញ្ញា Yumiko Hirakata មកពី NPO ASEAN Community Japan។




កំពូលជើងឯកជ័យលាភីលេខ១

ការប្រលងចម្រៀងជាភាសាជប៉ុនត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំក្នុងគោលបំណង ជម្រុញការសិក្សាភាសាជប៉ុននៅប្រទេសកម្ពុជា ជាពិសេសគឺផ្តល់ឱកាសដល់សិស្សដែលសិក្សាភាជប៉ុនបង្ហាញនូវទេព្យកោសល្យរបស់ពួកគេ ក្នុងវិស័យវប្បធម៌ និងសិល្បៈ។

ការប្រឡងចម្រៀងណូដូជីម៉ាន់ប្រចាំឆ្នាំ នឹងធ្វើឡើងនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៦នាពេលខាងមុខនេះ នៅCJCC។ យើងរំពឹងថាការយល់ដឹងពីវប្បធម៌ និង ភាសាជប៉ុនក្នុងចំណោម



ជ័យលាភីជើងឯកលេខ២

សិស្សានុសិស្សកម្ពុជានឹងត្រូវបានជម្រុញបន្ថែមតាមរយៈព្រឹត្តិការណ៍នេះ។

---

Embassy of Japan in the Kingdom of Cambodia

Tel: 023 217 161, Fax: 023 210 384, Official Website: www.kh.emb-japan.go.jp